# ឥទ្ធិពលដែលជំរឿនឆ្នាំ 2020 មានចំពោះសហគមន៍របស់អ្នក

NORTH CAROLINA
ASIAN AMERICANS TOGETHER

*www.ncaatogether.org/census*

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ ផ្នែកជំរឿនរបស់យើងតាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ [www.CountUsIn2020.org/hotline](http://www.CountUsIn2020.org/hotline) សម្រាប់ព័ត៌មានបន្ថែម។*

## ការពារបច្ចុប្បន្នកាល វិនិយោគអនាគតកាល

ទិន្នន័យជំរឿនជួយធានាថាគ្រួសារ និង សហគមន៍របស់អ្នកអាចរីកចម្រើនទៅមុខបានតាមរយៈថវិកា ជាង **$ 1.5 លានលាន**របស់សហព័ន្ធដែលត្រូវបានបម្រុងទុកជារៀងរាល់ឆ្នាំសម្រាប់ សហគមន៍។

*តើវានឹងផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់សហគមន៍របស់អ្នក?*

- Medicaid និង Medicare
- ជំនួយខាងផ្លូវ ថ្នល់
- ប័ណ្ណស្នាក់នៅផ្នែកទី 8
- កម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម
- Head Start
- ជំនួយពិសេសខាងការអប់រំ
- ជំនួយថែទាំកុមារ និង ជំនួយប្លុកអភិវឌ្ឍន៍
- បណ្ណាល័យ និង មន្ទីរពេទ្យ
- ព្រមទាំងអត្ថប្រយោជន៍ជាច្រើនទៀត

## ស្វែងរកធនធានសម្រាប់សហគមន៍របស់អ្នក

មនុស្សម្នាក់ៗដែលត្រូវបានរាប់បញ្ចូលក្នុងសហគមន៍របស់អ្នកសំដៅទៅលើថវិកាបន្ថែមដែល នឹងបានទទួល។ ផ្ទុយទៅវិញ បុគ្គលម្នាក់ៗដែលមិនបានចូលរួមក្នុងជំរឿននេះធ្វើឱ្យសហគមន៍របស់ អ្នកខាតបង់ថវិការាប់ពាន់ដុល្លារជារៀងរាល់ឆ្នាំ។ ដោយសារជំរឿននេះកើតឡើងតែរៀងរាល់ 10 ឆ្នាំម្តង ការបាត់បង់នេះនឹងកើតឡើងជារៀងរាល់ឆ្នាំរហូតដល់ឆ្នាំ 2030 ដែលអាចនាំអោយបាត់ បង់ធនធានជាច្រើនទៀត។

ការចូលរួមក្នុងការធ្វើជំរឿនមានន័យថាអ្នកបានទាមទារចំណែកយុត្តិធម៌សម្រាប់សហគមន៍របស់អ្នក។ កុំធ្វើអោយបាត់បង់នូវអត្ថប្រយោជន៍ដែលសហគមន៍របស់អ្នកគួរតែទទួលបាន។

## ត្រូវប្រាកដចិត្តថាសហគមន៍របស់អ្នកមានរូបរាង

ទិន្នន័យជំរឿនមិនត្រឹមតែត្រូវបានប្រើដើម្បីកំណត់ការផ្តល់ជំនួយរបស់សហព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែដើម្បីជូនដំណឹងដល់អ្នកដែលធ្វើការសម្រេចចិត្តអំពីកន្លែងដែលត្រូវវិនិយោគធនធានផងដែរ។ ទិន្នន័យខាងអត្រាប្រជាជនមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសហគមន៍របស់អ្នក ពីព្រោះ ទិន្នន័យអាចប៉ះពាល់ដល់ការធ្វើផែនការ និង ការវិនិយោគ។

នៅពេលមានការរាប់សន្លឹកឆ្នោតជាក់លាក់

- សាលារៀនថ្នាក់មូលដ្ឋាននឹងដឹងថាកន្លែងណាដែលត្រូវសាងសង់សាលារៀនថ្មី ឬ ពង្រីកសាលារៀនដែលមានស្រាប់។
- រដ្ឋាភិបាលក្នុងតំបន់នឹងដឹងពីរបៀបរៀបចំផែនការសម្រាប់តម្រូវការខាងលំនៅដ្ឋាន
- អ្នកផ្តល់សេវាថែទាំសុខភាពនឹងដឹងពីប្រភេទនៃការថែទាំដែលពួកគេត្រូវការ ដើម្បីផ្តល់ អាទិភាពដល់ប្រជាជននៅជុំវិញពួកគេ។
- អ្នកធ្វើធុរ◌ៈកិច្ចនឹងដឹងថាតើត្រូវបើកហាង និង សេវាកម្មថ្មីនៅកន្លែងណា ហើយ

- អ្នកតស៊ូមតិនឹងមានទិន្នន័យដើម្បីព្រាង និង ជំរុញគោលនយោបាយដើម្បីជួយកែលម្អជីវិតរបស់សមាជិកសហគមន៍។

## ត្រូវបានរាប់បញ្ចូលសម្រាប់តំណាងនយោបាយ



ទិន្នន័យជំរឿនមានសារៈសំខាន់ណាស់ដើម្បីធានាសំលេងរបស់អ្នកនៅក្នុងរដ្ឋាភិបាល។ ទិន្នន័យ ត្រូវបានប្រើដើម្បី៖

- កំណត់ចំនួនអាសនៈនៅក្នុងសភាតំណាងរាស្ត្រនីមួយៗដែលតំណាងឱ្យអំណាចនយោបាយ សម្រាប់សហគមន៍របស់អ្នក។
- រៀបចំសារជាថ្មីនូវផែនទីនយោបាយគ្រប់កម្រិតរបស់រដ្ឋាភិបាល។
- ការពារអ្នកបោះឆ្នោតប្រឆាំងនឹងការរើសអើងពូជសាសន៍។
- ត្រូវប្រាកដថាយុតាធិការផ្តល់ជំនួយផ្នែកភាសាដល់អ្នកបោះឆ្នោត។

## រាល់ការឆ្លើយតបសុទ្ធតែមានសារៈសំខាន់សម្រាប់សហគមន៍របស់អ្នក

សហគមន៍មួយចំនួន "ពិបាកក្នុងការរាប់" ជាពិសេស --- នេះមានន័យថានៅក្នុងសហគមន៍ទាំងនេះមានមនុស្សជាច្រើនដែលមិនឆ្លើយតបទៅនឹងជំរឿន។ វាអាចនាំឱ្យមានចំនួនមិនជាក់លាក់ក្នុងជំរឿន - នៅពេលដែលចំនួនប្រជាជនដែលត្រូវបានកត់ត្រាក្នុងជំរឿនតិចជាងចំនួនពិតប្រាកដនៃប្រជាជនដែលរស់នៅក្នុងសហគមន៍។ សហគមន៍ដែលក្នុងប្រវត្តិសាស្រ្តមានការពិបាករាប់រួមមាន ពូជសាសន៍ និង ជនជាតិភាគតិច អ្នកជួល អ្នកដែលមានចំណេះដឹងខាងភាសាអង់គ្លេសតិចតួច ជនអន្តោប្រវេសន៍ និង កុមារតូចៗ និងទារកជាដើម។

**ពហុសមាគមន៍ AANHPI មានហានិភ័យដោយត្រូវបានរាប់មិនគ្រប់ចំនួនសម្រាប់ឆ្នាំជំរឿន 2020”**



**1 ក្នុងចំនួន 5**

ជនជាតិអាស៊ីអាមេរិកាំងរស់នៅក្នុងទីកន្លែងដែលពិបាកនឹងរាប់សម្រាប់ជំរឿន



**1 ក្នុងចំនួន 3**

ជនជាតិដើមកោះហាវ៉ៃ និងជនជាតិកោះប៉ាស៊ីហ្វិករស់ក្នុងទីកន្លែងដែលពិបាកនឹងរាប់សម្រាប់ជំរឿន

ជនជាតិអាស៊ីអាមេរិកាំង ជនជាតិដើមហាវ៉ៃ និង កោះប៉ាស៊ីហ្វិករស់នៅក្នុងតំបន់ដាច់ស្រយាល ដែលមានអត្រានៃភាពក្រីក្រ និង ភាពអត់ការងារខ្ពស់ ជួបបញ្ហាប្រឈមកាន់តែធំក្នុងការស្វែងរកលំនៅដ្ឋានមានស្ថេរភាព និង មានតំលៃសមរម្យ ទទួលបានការអប់រំទាប និង ឧបសគ្គខាងភាសាជាច្រើនទៀត។ ការរាប់ចំនួនដែលមិនជាក់លាក់នឹងនាំឱ្យមានការបាត់បង់ថវិការបស់សហព័ន្ធដែលអាចជួយដោះស្រាយតម្រូវការរបស់ជនជាតិអាស៊ីអាមេរិកាំង ជនជាតិដើមហាវ៉ៃ និង កោះប៉ាស៊ីហ្វិក។ ការចូលរួមរបស់បុគ្គលម្នាក់ៗនៅក្នុងជំរឿនពិតជាសំខាន់ណាស់ដើម្បីធានាថាសហគមន៍របស់យើងត្រូវបានគេរាប់បញ្ចូលទាំងស្រុងនៅឆ្នាំ 2020 និង ទទួលបានចំណែកយុត្តិធម៌របស់ពួកគេសម្រាប់ទសវត្សខាងមុខ។

*អ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីជំរឿននៅ [www.CountUsIn2020.org/resources](www.CountUsIn2020.org/resources)។*